R03183
TSL ~~Box 1~~ 4722



អំពីឈ្មោះ ញ៉ា

អតីតយោធាកងធំ បច្ចុប្បន្នជា វ.ត នៅកងសមាសភាព

ចម្លើយ : ឃួន - ស៊ុយ ហៅ ស៊ឹម អនុសេនា វ.ត ១២៤ កងពល ៣១០

---

១- ឃួន - ស៊ុយ ហៅ ស៊ឹម ថា ពីមុនមក វាមិនដែលស្គាល់ប្រវត្តិ របស់ ញ៉ា ទេ ។

២- ៧៤ កាលនោះ ញ៉ា ជា ក.ប អនុសេនាធំ ឯវាជា ក.ប វរៈសេនាតូច វាអប់រំ ចាត់តាំង ញ៉ា ជាបន្ត បន្ទាប់ រហូត ញ៉ា ព្រមចូលរួមធ្វើសកម្មភាពបំរើបក្ស ពលករជាមួយ •វា តាំងពី ៧៤ មក ។

៣- តួនាទីសំខាន់របស់ ញ៉ា កាលក្នុងសង្គ្រាមគឺ :

- បំផុសយុ.ជ ឱយរត់ចោលសមរភូមិ រត់ទៅផ្ទះ ដឹកនាំ អង្គភាពទៅអោយខ្មាំងកំទេច តាមការចាត់តាំង របស់វា - ស៊ឹម - ។

៤- ឃួន - ស៊ុយ ហៅ ស៊ឹម ពុំបានបញ្ជាក់អំពីសកម្មភាពបច្ចុប្បន្នរបស់ ញ៉ា ទេ ។

អំពីឈ្មោះ :-

១. ពៀប យោធា កងធំ បច្ចុប្បន្ន វ.ត ១១២ កងពល ៣១០

២. រុន កម្មាភិបាលអនុសេនាធំ វ.ត ១២៤ កងពល ៣១០

---

ចម្លើយ : ឃួន-ស៊ុយ ហៅ ស៊ីម អនុលេខា វ.ត ១២៤ កងពល ៣១០

---

១- ឃួន-ស៊ុយ ហៅ ស៊ីម មិនបានបញ្ជាក់អំពីប្រវត្តិសកម្មភាពរបស់ ពៀប ពីមុនមកទេ ។

២- នៅពេលទៀបចុះទៅធ្វើស្រែ វា -ស៊ីម- បានចាត់តាំងឈ្មោះ ពៀប ឱ្យទទួលភារៈ បំផ្លាញសំភារៈកសិកម្ម នៅតាមការដ្ឋាន ។

៣- ភារៈកិច្ចនេះ វាថា ពៀប មិនទាន់ចុះអនុវត្តឱ្យចេញសាច់ការជាក់ស្តែងនៅឡើយទេ ។

៤- រុន និង ពៀប បានទទួលការចាត់តាំងពី ឃួន-ស៊ុយ ហៅ ស៊ីម ឱ្យទៅទាក់ទងប្រជាជន នៅភូមិក្រវ៉ា ឃុំក្រវ៉ា ដើម្បីរកសំណាបឱ្យបាន ៤០ ស្លឹក យកមកស្ទូង ។ ដល់ថ្ងៃកំណត់ វា -ស៊ីម ផុតចាត់តាំងឱ្យពីរនាក់ - ពៀប និង រុន -ទៅយកទេ ធ្វើឱ្យខូចសំណាបប្រជាជនអស់ ៤០ ស្លឹក ។